# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

| | |
|---|---|
| សំណុំរឿងលេខ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ |
| ភាគីដាក់ឯកសារ | សហមេធាវីរបស់លោក នួន ជា |
| ដាក់ជូន | អង្គជំនុំជម្រះសាលាដំបូង |
| ភាសាដើម | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ | ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៦ |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Aug-2016, 10:34
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន

ឈ្មោះមន្ត្រីកត់ត្រា

ហត្ថលេខា

---

**សំណើសុំរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង**
**សុំឲ្យទទួលយកជាភស្តុតាងទាក់ទិននឹងសាក្សី 2-TCW-850**

---

**ដាក់ដោយ ÷**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE
លីវ សុវណ្ណា
ព្រុំ ផល្លា
Doreen CHEN
Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI
DY Socheata

**ផ្ញើជូន ÷**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ

**សហព្រះរាជអាជ្ញា÷**

ជា លាង
Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ព្រមទាំងការអនុវត្តក្នុងពេលថ្មីៗនេះរបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង ០០២/០២[1] សហមេធាវីការពារក្តីរបស់លោក នួន ជា ("មេធាវីការពារក្តី") សូមដាក់សំណើនេះជូនអង្គជំនុំជម្រះសាលាដំបូង សុំឱ្យទទួលស្គាល់ឯកសារមួយដែលនឹងអាចត្រូវបានប្រើសម្រាប់ការសួរដេញដោលសាក្សី 2-TCW-850។

## II. សាវតារ

2. ដោយយោងទៅលើកាលវិភាគដែលចែកជូនភាគីក្នុងពេលថ្មីៗនេះដោយអង្គជំនុំជម្រះសាលាដំបូង សាក្សី 2-TCW-850 និងមកផ្តល់សក្ខីកម្មនៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦[2]។

## III. ច្បាប់ជាធរមាន

3. អនុលោមតាមវិធាន ៨៧(១) រាល់ភស្តុតាងទាំងអស់ត្រូវបានទទួលយក លើកលែងតែមានចែងនៅក្នុងវិធានផ្ទៃក្នុង។ វិធាន ៨៧(៣) ចែងថា អង្គជំនុំជម្រះអាចបដិសេធសំណើទទួលយកភស្តុតាងក្នុងករណីដែលខ្លួនយល់ឃើញថា ភស្តុតាងមិនមានភាពពាក់ព័ន្ធ ឬក៏ច្រំដែល មិនអាចរកបានក្នុងពេលវេលាសមស្រប មិនអាចបង្ហាញទៅលើអង្គហេតុដែលខ្លួនអាចបង្ហាញ មិនអនុញ្ញាតដោយច្បាប់ ឬក៏នាំឱ្យពន្យារពេលដំណើរការ ឬក៏មិនមានប្រយោជន៍។ ដើម្បីបំពេញលក្ខខណ្ឌនៃវិធាន ៨៧(៣) ភស្តុតាងត្រូវបានស្នើត្រូវការតែមានភាពពាក់ព័ន្ធ និងអាចជឿជាក់បានតាម*ការពិនិត្យបឋម*[3]។

---

[1] រយៈពេលមួយឆ្នាំសម្រាប់សំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានសម្រេចថា ភាគីត្រូវតែធ្វើសំណើជាផ្លូវការតាមវិធាន ៨៧(៤) ស្នើសុំឯកសារ ដែលមិនទាន់ទទួលស្គាល់ជាភស្តុតាង *នៅមុនពេល* ប្រើប្រាស់ក្នុងការសួរសាក្សី បើទោះជាឯកសារនោះមានក្នុងសំណុំរឿង ហើយត្រូវបានជូនដំណឹងដល់ភាគីនៅមុនពេលការមកផ្តល់សក្ខីកម្មរបស់សាក្សីក៏ដោយ។ *សូមមើល* ប្រតិចារិកសវនាការ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ (សេចក្តីសម្រេចរបស់ អជសដ) ទំព័រ ២៤ បន្ទាត់ ៨ ដល់ ១៧។

[2] សារអេឡិចត្រូនិចរបស់មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងជូនភាគីនៅថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០១៦។

[3] ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E289) និងចម្លើយតបរបស់ខៀវសំផន (ឯកសារ **E289/1** )" ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣, ៦ ("សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)")។

4. ដោយអនុលោមតាមវិធាន ៨៧ (៤) នៅក្នុងដំណាក់កាលណាក៏ដោយនៅក្នុងអំឡុងពេលសវនាការ ភាគីអាចស្នើសុំឱ្យអង្គជំនុំជម្រះ "ទទួលយកភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត" ដែលជាកម្មវត្ថុនៃភាពតម្រូវនៃវិធាន៨៧(៣) ។

5. ខណៈដែលវិធាន ៨៧(៤) ចែងថា ភស្តុតាងដែលត្រូវបានស្នើត្រូវតែមិនអាចរកបាននៅមុនពេលបើកសវនាការ[4] អង្គជំនុំជម្រះនេះបកស្រាយថា វាជាភស្តុតាងដែលអាចរកបាននៅមុនពេលចាប់ផ្តើមសវនាការ ប៉ុន្តែមិនអាចរកឃើញដោយមានការយកចិត្តទុកដាក់សមស្របនឹងអាចទទួលយក[5] ។ អង្គជំនុំជម្រះបានសម្រេចថា នៅពេលដែលភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់បុគ្គលត្រូវបានរកឃើញ ប៉ុន្តែដោយតាមរយៈ "ព័ត៌មានតិចតួចបំផុត" នៅមុនពេលបើកសវនាការ ហើយព័ត៌មានលម្អិតបន្ថែមទៀតគឺអាចរកបានតែនៅបន្ទាប់ពីការបើកសវនារការ ដែលសក្ខីកម្មបែបនេះនឹងត្រូវពិចារណាដោយអង្គជំនុំជម្រះថា មិនអាចរកបាននៅមុនពេលបើកសវនាការ[6]។

6. នៅពេលដែលភស្តុតាងអាចរកបាននៅមុនពេលបើកសវនាការ អង្គជំនុំជម្រះធ្លាប់បានសម្រេចថា ខ្លួនអាចទទួលយក នៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យមាន ជាពិសេសនៅពេលដែលភស្តុតាងដែលលើកឡើងជាភស្តុតាងដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃ ដើម្បីកុំឱ្យប៉ះពាល់ដល់យុត្តិធម៌[7], និងនៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យមានប្រភពដើម្បីវាយតម្លៃ[8] ឬក៏

---

[4] អង្គជំនុំជម្រះបានបញ្ជាក់ថា ការបើកសវនាការសម្រាប់សំណុំរឿង ០០២ នៅពេលសវនាការបឋមដែលបានចាប់ផ្តើមនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១។ ឯកសារ **E307/1** "សេចក្តីសម្រេចលើសំណើរួម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤ កឋាខណ្ឌ ២។ **E307/1/2** "សេចក្តីសម្រេចលើសំណើរួមសុំឱ្យសម្រេច *សាជាថ្មីឡើងវិញ* លើការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង" ថ្ងៃទី២១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៦។

[5] ឯកសារ **E313** "សាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២៥។ ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)" កថាខណ្ឌ ៣។

[6] ប្រតិចារិកសវនាការ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ (សេចក្តីសម្រេច អជសដ **E1/363.1**) ទំព័រ ៤៩ បន្ទាត់ ២ ដល់ ៨។

[7] ឯកសារ **E307/1** "សេចក្តីសម្រេចលើសំណើរួម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤ កឋាខណ្ឌ ៣។ ឯកសារ **E190** " សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត" កថាខណ្ឌ ៣៦។ សូមមើល ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)" កថាខណ្ឌ ៣។

[8] សូមមើល ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)" កថាខណ្ឌ ៣។ ឯកសារ **E190** " សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត" កថាខណ្ឌ ៣២។

នៅពេលដែលភាគីផ្សេងទៀតមិនបានបដិសេធនឹងភស្តុតាង[9]។

7. នៅក្នុងសារអេឡិចត្រូនិចកាលពីថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ទៅភាគីថា:

> [សំណើជាផ្លូវការអនុលោមតាមវិធាន ៨៧(៤) របស់ភាគី] ត្រូវតែបង្ហាញឯកសារជាក់លាក់ និងថាការស្នើសុំឲ្យទទួលយកជាភស្តុតាងត្រូវធ្វើឡើង ចំពោះចម្លើយកាលពីលើកមុនរបស់បុគ្គលដែលនឹងផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២។ មិនចាំបាច់បង្ហាញហេតុផលនោះទេ[10]។

## IV. អំណះអំណាង

8. ឯកសារដែលបានស្នើនេះមានលេខ **E319/33.3.9** ជាកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី 2-TCW-850 ដែលនឹងមកផ្តល់សក្ខីកម្មនៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦។

## V. **សំណើ**

9. អាស្រ័យដូចបានរៀបរាប់ក្នុងសំអាងហេតុខាងលើ មេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកឯកសារ **E319/33.3.9** ជាភស្តុតាងក្នុងសំណុំរឿង ០០២/០២។

សហមេធាវីការពារក្តី នួន ជា

សុន អរុណ Victor KOPPE

[9] សូមមើល ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)" កថាខណ្ឌ ៣។

[10] សារអេឡិចត្រូនិចពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងជូនភាគី ថ្ងៃទី២ ខែ មិថុនា ឆ្នាំ២០១៦ (ឯកសារភ្ជាប់ ១) ។